# សេវាកម្មជំនួយផ្នែកភាសា

RTD កំពុងធ្វើការសិក្សាអំពីតម្លៃបណ្ដាញប្រព័ន្ធ និងការវិភាគភាគហ៊ុន ដើម្បីថ្លឹងថ្លែងពីតម្លៃរបស់វា។
ពួកយើងស្វាគមន៍ការចូលរួម និងមតិកែលម្អរបស់អ្នក។
សេវាកម្មជំនួយផ្នែកភាសានឹងត្រូវបានផ្ដល់ជូនដោយមិនគិតថ្លៃ។ ប្រសិនបើអ្នកចង់ចូលរួម
ឬចង់បានព័ត៌មានបន្ថែម សូមផ្ញើអ៊ីមែលមក farestudy@rtd-denver.com ឬទូរស័ព្ទមក 303.299.6000។
ម្យ៉ាងវិញទៀត ធ្វើតាមការណែនាំខាងក្រោមដើម្បីផ្លាស់ប្ដូរភាសារកម្មវិធីរុករកតាមអ៊ីនធឺណិតរបស់អ្នក
ពីភាសាអង់គ្លេសទៅជាភាសាដែលអ្នកពេញចិត្ត។ បន្ទាប់មក ត្រឡប់ទៅគេហទំព័រ សិក្សាអំពីតម្លៃ នៅ
rtd-denver.com/farestudy សម្រាប់បច្ចុប្បន្នភាពនៃគម្រោង និងដើម្បីចូលរួម។

# របៀបប្ដូរភាសានៃកម្មវិធីរុករកតាមអ៊ីនធឺណិតរបស់អ្នក


Google Chrome ........ 1
Mozilla Firefox ........ 4
Microsoft Edge ........ 6
Apple Safari ........ 9


## Google Chrome

1. បើកកម្មវិធីរុករក Google Chrome។
2. នៅជ្រុងខាងស្ដាំផ្នែកខាងលើនៃវិនដូ សូមចុចរូប ⋮ ។
3. ពីម៉ឺនុយធ្លាក់ចុះដែលបង្ហាញ សូមជ្រើសរើស **Settings** ។
4. នៅក្នុងវិនដូបន្ទាប់ សូមចុចម៉ឺនុយធ្លាក់ចុះ Advanced ។
5. ចុចលើផ្នែក *Languages* ។

6. នៅក្នុងផ្នែក*Languages*សូមចុច**សញ្ញាព្រួញធ្លាក់ចុះ**នៅផ្នែកខាងស្ដាំនៃជម្រើស *Languages*។




7. នៅក្នុងម៉ឺនុយដែលបង្ហាញ សូមចុចតំណ Add languages ។

8. នៅក្នុងអេក្រង់បន្ទាប់ សូមចុចប្រអប់ធីកដែលនៅជាប់ភាសាមួយ ឬច្រើន (A) បន្ទាប់មកចុចប៊ូតុង**Add** (B)។



9. ភាសាដែលអ្នកបានជ្រើសរើសថ្មីៗគួរតែបង្ហាញនៅក្នុងម៉ឺនុយ*ភាសា*។ ដើម្បីជ្រើសរើសភាសាមួយ សូមចុចរូប ⋮ មួយផ្នែកខាងស្ដាំនៃភាសា រួចធីកប្រអប់នៅជាប់ **Display Google Chrome in this language** ។




10. ចុច **Relaunch** ឬបិទ ហើយបើកកម្មវិធីរុករក Chrome របស់អ្នកឡើងវិញ ដើម្បីបង្ហាញភាសាថ្មី។

# Mozilla Firefox

1. បើកកម្មវិធីរុករក Mozilla Firefox។
2. ចុចរូប  នៅជ្រុងខាងឆ្វេងផ្នែកខាងលើនៃវិនដូកម្មវិធីរុករក។
3. ជ្រើសរើស**Settings**ពីម៉ឺនុយធ្លាក់ចុះដែលបង្ហាញ។
4. ខាងក្រោមផ្នែក*Language*សូមចុចប៊ូតុង Choose... ។




5. នៅក្នុងវិនដូ សូមចុច **Select a language to add** ។



6. ចុចភាសាដែលអ្នកចង់បញ្ចូល (A) ចុច **Add** បន្ទាប់មកចុចប៊ូតុង **OK** (B)។




7. ចាប់ផ្តើមកម្មវិធីរុករករបស់អ្នកឡើងវិញ ដើម្បីបង្ហាញភាសាថ្មី។

# Microsoft Edge

1. បើកកម្មវិធីរុករក Microsoft Edge។
2. ចុច**រូបការកំណត់ និងច្រើនទៀត** ... នៅក្នុងជ្រុងខាងស្តាំផ្នែកខាងលើនៃវិនដូកម្មវិធីរុករក។
3. នៅក្នុងម៉ឺនុយធ្លាក់ចុះ នៅជិតប៊ូតុង សូមជ្រើសរើស**Settings**។



4. នៅផ្នែកខាងឆ្វេងនៃអេក្រង់ នៅក្នុងក្រោម*Settings*សូមចុច**Languages**។




5. នៅក្រោមផ្នែក*Languages* សូមចុចប៊ូតុង **Add languages**។



6. នៅក្នុងសារដែលបង្ហាញ សូមជ្រើសរើសភាសាដែលអ្នកចង់ឱ្យកម្មវិធីរុករកបង្ហាញ បន្ទាប់មកចុចប៊ូតុង **Add**។




7. ត្រឡប់នៅក្នុងផ្នែកភាសា សូមកំណត់ទីតាំងភាសាដែលអ្នកចង់ប្រើ រួចចុចរូប ... នៅផ្នែកខាងស្តាំ។ បន្ទាប់មក ធីកប្រអប់នៅជាប់ **Display Microsoft Edge in this language**។
8. ចុចប៊ូតុង Restart ឬបិទ ហើយបើកកម្មវិធីរុករកឡើងវិញ។

# Apple Safari

Safari ត្រូវបានរួមបញ្ចូលទៅក្នុង macOS។ បន្ទាប់មក អ្នកត្រូវចូលទៅក្នុងការកំណត់ភាសា Mac របស់អ្នក ដើម្បីប្តូរភាសាដែលបង្ហាញនៅក្នុង Safari។

1. នៅជ្រុងខាងឆ្វេងផ្នែកខាងលើនៃអេក្រង់ សូមចុចរូប Apple ដើម្បីបើកម៉ឺនុយ Apple រួចជ្រើសរើស**System Preferences**។




2. ចុច **Language & Region** នៅក្នុងវិនដូ*System Preferences*។



3. នៅក្នុងម៉ឺនុយ*Language & Region* នៅខាងក្រោម **Preferred languages**, សូមចុច **សញ្ញា +** នៅផ្នែកខាងក្រោម។




4. នៅក្នុងម៉ឺនុយធ្លាក់ចុះ សូមជ្រើសរើសភាសា បន្ទាប់មកចុចប៊ូតុង **Add**។



5. អ្នកគួរតែត្រូវបានជំរុញឱ្យប្តូរទៅភាសាថ្មី។ ប្រសិនបើមិនអញ្ចឹងទេ សូមចុចហើយអូសភាសាថ្មីទៅផ្នែកខាងលើនៃម៉ឺនុយនៅលើអេក្រង់មុន (បង្ហាញនៅក្នុងជំហានទី 3)។




6. ចុចប៊ូតុង **Restart Now** សម្រាប់ការកំណត់ភាសាថ្មី ដើម្បីឱ្យមានប្រសិទ្ធភាព។

